សប្តាហ៍ទី 23

ដាវីឌ និងយ៉ូណាថាន

យ៉ូណាថានស្រឡាញ់ដាវីឌអស់ពីចិត្ត ហើយបានក្លាយជាមិត្តនឹងគ្នា

រឿងក្នុងព្រះគម្ពីរ

ពេលយ៉ូណាថានឃើញដាវីឌ គាត់បានដឹងថាព្រះគង់ជាមួយនឹងដាវីឌ។

យ៉ូណាថានស្រឡាញ់ដាវីឌអស់ពីចិត្ត ហើយបានក្លាយជាមិត្តនឹងគ្នា

គេបានសន្យាថានឹងជួយគ្នាទៅវិញទៅមក ដោយចិត្តនៃក្តីជំនឿលើព្រះ។

យើងក៏ត្រូវចេះស្រឡាញ់គ្នា ចេះជួយគ្នា និងមានទំនាក់ទំនងល្អជាមួយគ្នាដែរ!

សមិទ្ធផលសម្រេច



យើងក៏ត្រូវចេះស្រឡាញ់គ្នាទៅវិញទៅមក និងធ្វើជាមិត្តល្អនៅក្នុងព្រះអម្ចាស់ ដូចដាវីឌនិងយ៉ូណាថានដែរ!

វត្ថុបំណង

- រៀនពីក្តីស្រឡាញ់ព្រះជាម្ចាស់តាមរយៈក្តីស្រឡាញ់របស់ដាវីឌ និងយ៉ូណាថាន
- មានដួងចិត្តស្រឡាញ់មិត្តភក្តិ និងជួយគ្នាទៅវិញទៅមក
- បណ្តុះភាពច្នៃប្រឌិត និងការបង្ហាញគំនិតអារម្មណ៍ តាមរយៈការតុបតែងកងដៃ
- ចែកចាយក្តីស្រឡាញ់ជាមួយមិត្តភក្តិ ដោយប្តូរកងដៃគ្នា។

សម្ភារៈ



×សូមប្រើប្រាស់គម្រូរូបភាពដែលមាននៅក្នុងឯកសារសម្ភារៈសម្រាប់គ្រូបង្រៀន។

របៀបធ្វើ

1 ការកាត់ស្នូលក្រដាស



កាត់ស្នូលក្រដាសអនាម័យជាពីរ រួចព័ត៌វាចូលគ្នាឱ្យមានរាងដូចកងដៃ។

2 ការបិទក្រដាសពណ៌



បិទក្រដាសពណ៌ ឬក្រដាសឆ្នូតៗ នៅផ្នែកខាងក្រៅនៃកងដៃ។

3 ការតុបតែង



បិទស្ទីគ័រ ស្ទីគ័រត្បូង សុតពណ៌ តុបតែងវាឱ្យបានស្អាត។

4 ការសរសេរ និងគូររូប



សរសេរឈ្មោះមិត្តភក្តិ ឬពាក្យលើកទឹកចិត្ត។
ឧ, ខ្ញុំស្រឡាញ់មិត្ត!

5 ការភ្ជាប់កងដៃ



ទាញចុងសងខាងកងដៃឱ្យជិតគ្នា រួចបិទភ្ជាប់ដោយប្រើស្កុត នោះកងដៃនឹងរួចរាល់!

6 ការប្តូរជាមួយមិត្តភក្តិ



ប្តូរកងដៃគ្នាជាមួយមិត្តភក្តិដើម្បីចែកចាយក្តីស្រឡាញ់!

ការពង្រីកសកម្មភាព



- **ការបង្កើតឈុតកងដៃនៃក្តីស្រឡាញ់**
  ធ្វើកងដៃឱ្យច្រើនម៉ូតច្រើនពណ៌ រួចយកទៅឱ្យគ្រួសារ ឬមិត្តភក្តិ។
- **ការសរសេរសារលើកទឹកចិត្ត**
  សរសេរពាក្យសរសើរ ឬពាក្យលើកទឹកចិត្តមិត្តភក្តិ នៅផ្នែកខាងក្នុងនៃកងដៃ។
- **ការតុបតែងបណ្តុំអរគុណ**
  ជូនកងដៃ រួមជាមួយនឹងបណ្តុំដែលសរសេរពាក្យអរគុណ បង្ហាញពីដួងចិត្តទៅកាន់មិត្តភក្តិ។

Tip សម្រាប់គ្រូ

- សូមលើកទឹកចិត្តឱ្យកុមារជ្រើសរើសពណ៌ដោយខ្លួនឯង។
- សូមជួយកុមារឱ្យសរសេរឈ្មោះមិត្តភក្តិបានត្រឹមត្រូវ និងពាក្យល្អៗ។
- ចំពោះសម្ភារៈ សូមត្រៀមឱ្យច្រើនប្រភេទ ដោយគោរពចំពោះលក្ខណៈពិសេសរបស់សិស្សម្នាក់ៗ។
- សូមធ្វើឱ្យវាក្លាយជាពេលវេលាដែលអាច ឱ្យកុមារមានអារម្មណ៍ពីតម្លៃរបស់មិត្តភក្តិ ពេលប្តូរកងដៃគ្នា។
- សូមឱ្យកុមារចែករំលែកក្តីស្រឡាញ់គ្នា ដោយសរសើរកងដៃរបស់គ្នាទៅវិញទៅមក បន្ទាប់ពីចប់សកម្មភាព។

